# សុខភាព និងសុខុមាលភាពរបស់ស្ត្រី



អស់រយៈពេលជាយូរហើយ ដែលសុខភាពរបស់ស្ត្រីត្រូវបានគេមើលរំលង។ យើងត្រូវតែកែលម្អឱ្យបានកាន់តែប្រសើរ ដើម្បីឱ្យក្មេងស្រី ស្ត្រី និងមនុស្សដែលមានយ៉េនឌ័រចម្រុះអាចទទួលបានការថែទាំកាន់តែប្រសើរ ព័ត៌មានកាន់តែប្រសើរ និងលទ្ធផលសុខភាពកាន់តែប្រសើរតាមរយៈសេវាកម្មសុខភាពរបស់ស្ត្រីដោយឥតគិតថ្លៃនៅទូទាំងរដ្ឋវិចថូរៀ។

យើងកំពុងកែលម្អប្រព័ន្ធនេះ ដើម្បីឱ្យអ្នកអាចកែលម្អសុខភាពរបស់អ្នកបានប្រសើរផងដែរ។

## ការថែទាំសុខភាពស្ត្រីដោយឥតគិតថ្លៃ

ស្ត្រីនៅទូទាំងរដ្ឋវិចថូរៀ ឥឡូវនេះអាចទទួលបានការថែទាំសុខភាពឯកទេសដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបសម្រាប់ស្ថានភាពសុខភាពរបស់ស្ត្រី រួមមាន៖

- ការឈឺត្រគាក
- រោគរ៉ាំរ៉ៃនៃភ្នាសស្បូនលូតលាស់នៅក្រៅស្បូន
- ការមិនអាចគ្រប់គ្រងការបន្ទោបង់លាមក ឬទឹកនោម
- ការអស់រដូវ
- ការហូរឈាមច្រើន
- ការធ្វើតេស្ត និងព្យាបាលសុខភាពផ្លូវភេទ
- ការថែទាំការរំលូតកូន

### គ្លីនិកពិនិត្យសុខភាពស្ត្រី

ការថែទាំឯកទេសសម្រាប់ស្ថានភាពសុខភាពស្ត្រី រួមទាំងរោគរ៉ាំរ៉ៃនៃភ្នាសស្បូនលូតលាស់នៅក្រៅស្បូន ការឈឺត្រគាក ការហូរឈាមច្រើន ការស្រុតស្បូន ការគ្រប់គ្រងការអស់រដូវ ការថែទាំពេលរំលូតកូន និងការពន្យារកំណើត។

### គ្លីនិកពិនិត្យសុខភាពស្ត្រីតាមបែបនិម្មិត

ការថែទាំឯកទេសតាមទូរសព្ទ ឬការណាត់ជួបតាមវីដេអូ។ អ្នកអាចទទួលបានការថែទាំពីផ្ទះរបស់អ្នក ឬពីទីកន្លែងណាមួយ។

### មជ្ឈមណ្ឌលសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ស្ត្រី

ថែទាំសម្រាប់បញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំងការពន្យារកំណើតគ្រប់ប្រភេទ ការធ្វើតេស្ត និងព្យាបាលសុខភាពផ្លូវភេទ និងជម្រើសមានផ្ទៃពោះដូចជាការថែទាំការរំលូតកូន។

### គ្លីនិកពិនិត្យសុខភាពស្ត្រីចល័ត

សេវាកម្មធ្វើដំណើរសម្រាប់សហគមន៍នៅតាមជនបទ និងតាមតំបន់។ វាផ្តល់ដំបូន្មាន ការគាំទ្រ និងការត្រួតពិនិត្យសុខភាពសំខាន់ៗ ដូចជាការពិនិត្យមាត់ស្បូន និងការពិនិត្យពោះវៀន។

ដើម្បីស្វែងរកគ្លីនិកដែលនៅជិតអ្នកបំផុត និងរកមើលសេវាកម្មនានាដែលមាន សូមចូលមើលគេហទំព័រ womenshealth.vic.gov.au

Women's Health and Wellbeing Program

VICTORIA State Government | Department of Health